**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ.....០១...សសរ**

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកិច្ចសន្យាស្តីពីការជួសជុលពហុកីឡាដ្ឋានជាតិអូឡាំពិក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតលេខ ១៧៤៧ សជណ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញលិខិតលេខ ១៨៨៧ សជណ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យ និងដោះស្រាយភាពមិនប្រក្រតី និងបញ្ហាពាក់ព័ន្ធនឹងកិច្ចសន្យាស្តីពីការជួសជុលពហុកីឡាដ្ឋានជាតិអូឡាំពិក ដែលមានសមាសភាពដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **អ៊ឹម សិទ្ធី** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | ប្រធាន |
| ២. | ឯកឧត្តម | **គង់ វិបុល** | រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម | **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |

៤. ឯកឧត្តម ហ៊ី សោភា រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

៥. ឯកឧត្តម ម៉ម សុផាណា អនុរដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦. ឯកឧត្តម សម សុផល អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

៧. ឯកឧត្តម សួន សិរិទ្ធ អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៨. ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី នាយកខុទ្ទកាល័យ-ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សមាជិក

៩. ឯកឧត្តម ជួប សំភី សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

១០. ឯកឧត្តម ជា អឿង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១១. លោក អ៊ុន ទ៉ាល់ឡី ប្រធាននាយកដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១២. លោក សួន រិទ្ធី នាយករងខុទ្ទកាល័យ សាលាក្រុងភ្នំពេញ សមាជិក

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម:

១. ពិនិត្យសុពលភាពនៃកិច្ចសន្យាស្តីពីការជួសជុល និងស្តារឡើងវិញពហុកីឡាដ្ឋានជាតិអូឡាំពិក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០០ ព្រមទាំងសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យានេះ

២. សិក្សាស្រាវជ្រាវ និងលើកយោបល់ជូនរាជរដ្ឋាភិបាលអំពីនីតិវិធីនៃច្បាប់ដ៏សមស្រប ដើម្បីលុបកិច្ចសន្យានេះចោល

៣. ដោះស្រាយបញ្ហាពាក់ព័ន្ធមួយចំនួន ដូចជាទីតាំងសាងសង់រួច ទីតាំងកំពុងសាងសង់ និងបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យាខាងលើ ។

**ប្រការ ៣** : គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងាររបស់ខ្លួន ។

**ប្រការ ៤** : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សាលាក្រុងភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧

ហ៊ុន សែន

ចំលងជូន :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៥

-ក្រុមហ៊ុន យាន តាយ សំណង់វិស្វកម្ម

-ឯកសា-កាលប្បវត្តិ